
Kids of Destiny
Reaching the Next Generation
www.kidsofdestiny.org

# 4.09 **ស្តេចដាវីឌខ្វល់ខ្វាយពីរឿងកូនប្រុសរបស់យ៉ូណាថាន**

នៅពេលចុងក្រោយ ដាវីឌ និងយ៉ូណាថាន ជាបុត្រារបស់ស្តេចសូល ក៏មានការព្រមព្រៀងគ្នាដើម្បីថែរក្សាមិត្តភាពជាមួយគ្នា រហូតតដល់កូនចៅរបស់ពួកគេ ។ យ៉ូណាថាន និងដាវីឌគឺជាមិត្តដ៏ល្អបំផុត។ យ៉ូណាថានបានជួយដល់ដាវីឌ ឲ្យបានគេចផុតពីស្តេចសូល នៅពេលដែលស្តេចចង់តាមសម្លាប់គាត់។ យ៉ូណាថានតែងតែចង់ឲ្យដាវីឌជាស្តេច ជំនួសគាត់ខ្លួនឯងផ្ទាល់។ ជាច្រើនឆ្នាំកន្លងផុតទៅ មានចម្បាំងជាច្រើនបំផុត។ មានពេលជាច្រើនបំផុត នៅពេលដែលដាវីឌ បានរត់គេចចេញពីក្រញាំដៃស្តេចសូល។ ប៉ុន្តែ ដាវីឌមិនដែលបានតបស្នងសេចក្តីអាក្រក់ដល់ ស្តេចឡើយ។ ដាវីឌបានដឹងថា ព្រះអម្ចាស់ដ៏ជាព្រះទ្រង់បានតាំងសូលធ្វើជាស្តេចសម្រាប់ពេលវេលានោះ។ ដាវីឌមានសេចក្តីស្មោះត្រង់ ដល់ការជ្រើសរើសរបស់ព្រះ។ សូម្បីតែដាវីឌមានពេលអាចនឹងកម្ចាត់ស្តេចសូលក៏ដោយ តែគាត់នៅតែមិនធ្វើអ្វីឡើយ។ បន្ទាប់ពីមាសង្គ្រាម ជាច្រើនឆ្នាំកន្លងផុតទៅ នោះស្តេចសូល និងបុត្រារបស់ទ្រង់ យ៉ូណាថាន បានត្រូវទទួលការធ្វើឃាតពីខ្មាំងសត្រូវ។

យ៉ូណាថាន មានបុត្រតូចមួយ ដែលថ្វាយព្រះនាមថា ម៉ូភីបូសែត។ ម៉ូភីបូសែតត្រូវបានទទួលការចិញ្ចឹមបីបាច់ ដោយគិលានុបដ្ឋាយិកាម្នាក់ (គ្រូពេទ្យ)។ នៅពេលដែលបានឮដំណឹងមកថា ទាំងពីរអង្គគឺស្តេចសូលនិងយ៉ូណាថាន បានត្រូវសម្លាប់ហើយ គិលានុបដ្ឋាយិកានោះ ក៏បានត្រឡប់ទៅជាមានការតក់ស្លុត។ នាងក៏បានប្រញាប់ប្រញាល់ឆក់យកម៉ូភីបូសែតពររត់ចេញទៅ។ ពេលដែលនាងបានរត់ នាងបានរអិលដួលធ្វើឲ្យធ្លាក់ម៉ូភីបូសែត។ វាធ្វើឲ្យរូបកាយរបស់គាត់ទៅជាពិការ។ ជើងរបស់គាត់បណ្តាលឲ្យពិការអស់មួយជីវិត។ នៅពេលនោះ គាត់មានអាយុទើបតែ៥ឆ្នាំប៉ុណ្ណោះ។ ជាច្រើនឆ្នាំបានកន្លងផុតទៅ នគរក៏បានចែកទៅជាពីរផ្នែក។ មួយចំណែកហៅថា ស្រុកអ៊ីស្រាអែល មួយចំណែកទៀតហៅថា ស្រុកយូដា។ ឥឡូវនេះ ស្តេចដាវីឌគឺជាស្តេចយូដា។ ថ្ងៃមួយ ទ្រង់បានចាប់ផ្តើមនឹករឮកដល់មិនត្តរបស់ទ្រង់ គឺយ៉ូណាថាន។ នៅតែមានបុរសអ្នកបម្រើម្នាក់ ឈ្មោះ  ស៊ីបា ដែលបានធ្វើការនៅក្នុងដំណាក់ស្តេចសូល ដែលឥឡូវនេះ គាត់បានធ្វើការឲ្យស្តេចដាវីឌ។

ស្តេចដាវីឌ បានសួរថា «តើមានអ្នកណាម្នាក់ពីក្រុមគ្រួសារសូល បាននៅរស់ទេ? ខ្ញុំចង់បង្ហាញពីសេចក្តីសប្បុរស ស្រឡាញ់ដល់មិត្តសំឡាញ់របស់ខ្ញុំ គឺយ៉ូណាថាន»។ លោកស៊ីបា ជាអ្នកបម្រើស្តេចសូលបាននិយាយថា«ក្រាបទូល យ៉ូណាថានមានកូនប្រុសម្នាក់ឈ្មោះម៉ូភីបូសែត។ គាត់ជាមនុស្សពិការជើងទាំងពីរ។ អ្នកបម្រើបានដឹងថា ម៉ូភីបូសែតបានរស់នៅ ដាវីឌក៏មានបន្ទូលថា «ចូរទៅនាំយកគាត់មកនៅទីនេះ»។ ពេលដែល ម៉ូភីបូសែតបានជួបស្តេច ដាវីឌ គាត់បានក្រាបចុះចំពោះទ្រង់ ស្តេចដាវីឌបានមានបន្ទូលថា «កុំមានការតូចចិត្តធ្វើអី។ ខ្ញុំចង់ធ្វើការពិសេសខ្លះសម្រាប់អ្នក ពីព្រោះបិតារបស់អ្នកគឺជាមិត្តដ៏ល្អរបស់ខ្ញុំ។ ដើម្បីបានចាប់ផ្តើមនូវរឿងនេះ ខ្ញុំចង់ផ្តល់ឲ្យអ្នកនូវទ្រព្យសម្បត្តិទាំងអស់ ដែលជីតារបស់អ្នក គឺជាស្តេចសូលមាននៅសេសសល់ទាំងប៉ុន្មាន។ ខ្ញុំក៏ចង់ឲ្យអ្នកទទួលទានអាហារនៅតុរបស់ខ្ញុំឥឡូវនេះដែរ»។ ម៉ូភីបូសែត មិនចង់ជឿនូវអ្វីដែលបានកើតឡើងនេះទេ! គាត់មិនអាចសូម្បីតែក្រឡេកមើលព្រះភក្ត្ររបស់ស្តេចដាវីឌផង។ គាត់និយាយថា «ហេតុអ្វីបានជាទ្រង់ធ្វើយ៉ាងដូច្នេះចំពោះ ទូលបង្គំ? ទូលបង្គំមិនមែនជាមនុស្សសំខាន់អ្វីទេ»។

ស្តេចដាវីឌបានប្រាប់ទៅអ្នកបម្រើថា «របស់គ្រប់យ៉ាង ដែលជារបស់ស្តេចសូល និក្រុមគ្រួសាររបស់ទ្រង់ ឥឡូវនេះជារបស់ម៉ូភីបូសែតដែលជាចៅរបស់ទ្រង់ហើយ ។ អ្នកនិងក្រុមគ្រួសាររបស់អ្នក គឺត្រូវធ្វើជាអ្នកបម្រើដល់គាត់ ឥឡូវនេះ ចូរធ្វើស្រែចម្ការ នៅលើដី ហើយនាំយកភោគផលទាំងអស់សម្រាប់ម៉ូភីបូសែត។ ហើយឥឡូវនេះ ម៉ូភីបូសែតនឹងទទួលទានអាហារនៅតុរបស់ខ្ញុំជារហូតហើយ។ ស្តេចដាវីឌបានប្រាប់ទៅអ្នកបម្រើ ឈ្មោះស៊ីបាថា «គ្រប់យ៉ាងដែលជារបស់ស្តេចសូល និងក្រុមគ្រួសាររបស់ទ្រង់ ឥឡូវនេះជារបស់ម៉ូភីបូសែត ជាចៅរបស់ស្តេចសូលហើយ។ អ្នកនិងពួកកូនប្រុសរបស់អ្នកនឹងទៅជាអ្នកបម្រើរបស់ទ្រង់ហើយ ឥឡូវនេះ ចូរធ្វើស្រែ ចម្ការ នៅលើដីរបស់ទ្រង់ និងយកភោគផលទាំងអស់សម្រាប់ម៉ូភីបូសែតចុះ។ ហើយម៉ូភីបូសែត ឥឡូវនេះ ត្រូវទទួលទានរួមតុជាមួយខ្ញុំជារៀងរហូតទៅ»។

គ្រប់យ៉ាងដែលទ្រង់សុំឲ្យទូលបង្គំធ្វើដល់ស្តេចរបស់ទូលបង្គំ នោះទូលបង្គំនឹងធ្វើ អ្នកបម្រើបាននិយាយ ។ ដូច្នេះ ម៉ូភីបូសែតបានទទួលទានអាហាររួមតុជាមួយស្តេចដាវីឌ នៅក្រុងយេរូសាឡិម ដូចជាក្រុមគ្រួសាររបស់ស្តេច។ គាត់ក៏មានកូនប្រុសម្នាក់នៅជាមួយគាត់ដែរ ឈ្មោះថា មីកា ។ អស់អ្នកដែលមានចំណែកនៅក្នុងផ្ទះរបស់លោកស៊ីបា គឺជាបាវបម្រើរបស់ម៉ូភីបូសែត។ ស្តេចដាវីឌ ទ្រង់បានថែរក្សានូវសេចក្តីសន្យាជាមួយយ៉ូណាថាន ជាមិត្តភាពរហូតដល់កូនចៅ ។ **២ សាំយូអែល ៤:៤ ២សាំយូអេល ៩ពូក**

**ស្តេចដាវីឌខ្វល់ខ្វាយពីរឿងកូនប្រុសរបស់យ៉ូណាថាន** -

## 4.09 ការណែនាំរបស់គ្រូបង្រៀន៖
## កំណត់សម្គាល់៖

១) ស្តេចដាវីឌ និងកូនរបស់ស្តេចសូល យ៉ូណាថាន បានធ្វើជាមិត្តភក្តិដ៏ល្អនឹងគ្នា ក្នុងរយៈពេលតែមួយដងប៉ុណ្ណោះ។ គឺជាពេលចុងក្រោយដែលពួកគេបានជួបគ្នា ពួកគេបាននិយាយលាគ្នាទាំងទាំងមានការទុក្ខព្រួយ ប៉ុន្តែ ពួកគេបានដឹងថា ព្រះដ៏ជាព្រះទ្រង់ពិតជាប្រទានពរនូវចំណងមិត្តភាព រវាងពួកគេ និងកូនចៅរបស់ពួកគេ។
២) សូលនិងយ៉ូណាថាន បានស្លាប់ក្នុងពេលច្បាំងគ្នានៅក្នុងសមរភូមិ។ ដាវីឌបានគ្រឡប់ទៅជា ស្តេច។ មានអ្នកបម្រើបានធ្វើការសម្រាប់ទ្រង់ ឈ្មោះស៊ីបា ដែលជាអ្នកបម្រើរបស់ស្តេចសូល ។
៣) ស្តេចដាវីឌបាននឹកចាំពីមិត្តភក្តិរបស់ទ្រង់ ឈ្មោះ យ៉ូណាថាន ក្នុងរយៈពេលមួយថ្ងៃ។ ទ្រង់បានសួរស៊ីបាថា ប្រសិនបើមានអ្នកណាខ្លះ នៅក្នុងក្រុមគ្រួសាររបស់ស្តេចសូល ទ្រង់នឹងជួយ ដោយមានសេចក្តីស្រឡាញ់ដល់មិត្តភក្តិរបស់ទ្រង់ គឺយ៉ូណាថាន។ ស៊ីបាបានទូលប្រាប់ស្តេចថា យ៉ូណាថានមានបុត្រម្នាក់ម្នាក់ ឈ្មោះ ម៉ូភីបូសែត ដែលបានពិការជើងទាំងសងខាង។ ស្តេចដាវីឌ មានបន្ទូលថា «សូមនាំគាត់មកទីនេះ»។
៤) «អ្នកនឹងទទួលអាហារនៅតុរបស់យើង» ដាវីឌមានបន្ទូលទៅម៉ូភីបូសែត។ «ហើយអ្នកនឹងមានទ្រព្យសម្បត្តិទាំងអស់ដែលជាកម្មសិទ្ធិរបស់ជីតាអ្នក គឺជាស្តេចសូល»។ គាត់បានក្រាបចុះចំពោះស្តេចដាវីឌ ដើម្បីបង្ហាញនូវការគោរពរបស់គាត់។ គាត់ទូលទៅស្តេចដាវីឌថា គាត់គ្មានរូបកាយដែលសំខាន់ណាទេ។ «ហេតុអ្វីបានជាទ្រង់ធ្វើយ៉ាងដូច្នេះចំពោះទូលបង្គំ?»
៥) លោកស៊ីបា និងពួកកូនប្រុសរបស់គាត់ បានត្រឡប់ទៅជាអ្នកបម្រើដល់ព្រះអង្គម្ចាស់ ម៉ូភីបូសែត ហើយម៉ូភីបូសែត និងកូនប្រុសរបស់គាត់ឈ្មោះមីកា បានបរិភោគនៅតុរបស់ស្តេចដាវីឌ ដោយ សារតែពួកគេមានចំណែក នៃគ្រួសាររបស់ស្តេច ។

**សំណួរ៖**

1) លោកដាវីឌ និងយ៉ូណាថាន បានជួបគ្នាជាលើកចុងក្រោយ តើហេតុអ្វីទៅដែលព្រះទ្រង់បានធ្វើឲ្យពួកគេបានស្គាល់ជា យ៉ាងដូច្នោះ?
2) តើលោកស៊ីបាជាអ្នកណា?
3) តើអ្វីទៅដែលនាំឲ្យស្តេចដាវីឌចង់មានការចងចាំដល់យ៉ូណាថាន?
4) តើម៉ូភីបូសែតជាអ្នកណា?
5) តើស្តេចដាវីឌបានធ្វើអ្វីសម្រាប់ម៉ូភីបូសែត?

**ចម្លើយ៖**

1) យ៉ូណាថាន និងស្តេចដាវីឌបានស្គាល់គ្នា ដែលព្រះទ្រង់បានប្រទានពរ ជាមិត្តភាពរវាងពួកគេ និងកូនចៅរបស់ពួកគេ ។
2) លោកស៊ីបា ជាអ្នកបម្រើរបស់ស្តេចដាវីឌ ប៉ុន្តែគាត់ក៏បានធ្វើជាអ្នកបម្រើរបស់ស្តេចសូលផងដែរ ។
3) ស្តេចដាវីឌបានចង់ធ្វើរឿងរ៉ាវខ្លះសម្រាប់ក្រុមគ្រួសាររបស់ស្តេចសូលដោយក្តីស្រឡាញ់ដល់មិត្តភក្តិរបស់ទ្រង់ គឺយ៉ូណាថាន ។
4) ម៉ូភីបូសែត គឺជាកូនប្រុសរបស់យ៉ូណាថាន ។
5) ស្តេចដាវីឌបានប្រាប់ទៅម៉ូភីបូសែតថា គាត់និងកូនប្រុសរបស់គាត់ អាចទទួលទានអាហារនៅតុរបស់ទ្រង់។ ទ្រង់ក៏បានប្រទានដល់ម៉ូភីបូសែតផងដែរ នូវទ្រព្យសម្បត្តិទាំងអស់ ដែលជារបស់ជីតាគាត់ គឺជាស្តេចសូល។


Kids of Destiny
Reaching the Next Generation
www.kidsofdestiny.org